# ពាក្យកាព្យប្រដៅជនប្រុសស្រី

១ ខ្ញុំសូមបង្គំព្រះសម្មា សម្ពុទ្ធណាៗក្នុងត្រៃភព
ចំរើនកម្មដ្ឋានក្រោមពោធិ៍ម្លប់ ខ្ញុំសូមគោរពនមស្សការ។
ព្រះចមច្រកពិននិន្ទរិទ្ធិ ជាម្ចាស់ជីវិតលើសិរសា
សូមថ្វាយបង្គំព្រះករុណា សូមទ្រង់មេត្តាប្រោសប្រណី។
អោនកាយថ្វាយបង្គំប្រណម្យនឹក សូមក្រើនរំលឹកពាស្រ្តប្រុសស្រី
ធ្លាប់ជ្រកទីពឹងព្រះបារមី អោយរៀនបាលីទៅបរលោក។
សរណគមន៍បីអោយប្រតិបត្តិ កំចាយកំចាត់ក្តីទុក្ខសោក
រូបយើងសព្វថ្ងៃថ្លៃមិនថោក បានមកភពភាន់ទាន់សាសនា។
៥ ផ្លូវប្រេតនរកទៅញឹកញយ គួរកុំបណ្តោយតាមតណ្ហា
គួរគិតសង្វេបឃាត់សង្ខារ សង្ឃឹមព្រះសិអារ្យនឹងមកត្រាស់។
ជម្ពូទ្វីបនេះធំបំផុត មួយម៉ឺនយោជន៍គត់ដំណែលព្រះ
សត្វស្លាប់តាមកម្មមិនចាំចាស់ អាយុខ្លីណាស់ក្រាស់កុសល។
រូបំ អនិច្ចំ អនត្តា កើតរូបកាលណាកម្មតាមដល់
តាមដានដរាបបាបអោយផល បាបខ្លះសេសសល់ពីនរក។
ខ្លះមកអំពីប្រេតតិរិច្ឆាន ខ្លះមកពីស្ថានសួគ៌សោយសុខ
វេរតាមរកបានឃើញមុខ ចុះមករងទុក្ខទទួលកម្ម។
អ្នកធ្លាក់ទៅរងនរកប្រេត ដើមហេតុពីព្រោះដាច់សីល៥
ទឹកក្តៅខ្លះដេកទៅដេកត្រាំ រាប់លានកោដិឆ្នាំទំរាំរួច។

១០ មកកើតជាមនុស្សស្ថានកណ្តាល  មិនរាងមិនចាលដល់តិចតួច

ប្រពន្ធកូនគេនៅតែលួច  សត្វធំសត្វតូចរិតសំលាប់។

ស្រារឹតតែផឹកអោយស្រវឹង  គុណទោសមិនដឹងប្រឹងចាក់កាប់

ស្រេកឃ្លានបំពានធ្វើលើច្បាប់  មិនស្តាប់ពុទ្ធដិកាព្រះអង្គផ្តាំ។

ពិតមែនជាមិនលឺព្រះអោស្ឋ  ព្រះសង្ឃទ្រង់ប្រោសអោយសីល៥

ទទួលរំពេចភ្លេចមិនចាំ  ប្រព្រឹត្តសាងកម្មមិនព្រមលែង។

កើតមកពូជពង្សពេញជាមនុស្ស  សេចក្តីត្រូវខុសចាំជាក់ស្តែង

សំលាប់រូបសត្វអិតគិតក្រែង  បំពេញរូបអែងអោយធំធាត់។

សំលាប់មិនថាសត្វឈ្មោលញី  យកសាច់មកស៊ីអោយឆ្ងាញ់មាត់

ទទួលសីលភ្លើធ្វើអោយភ្លាត់  លក់សត្វអោយព្រាត់មេព្រាត់កូន។

១៥ ព្រាត់គូកំសត់វដ្តសង្សារ  ដូចលក់ជីតាលក់ជីដូន

ពុំនោះលក់បងបំបែកប្អូន  ងងឹតឈឹងសូន្យមើលមិនយល់។

ខ្លះទៅនរកមិនទាន់មក  ខ្លះឃ្លាតទៅជ្រកពួកអសុរ

ជវ៉នែសង្ខារលប់វិលវល់  អំពល់តែកើតស្លាប់កើតស្លាប់។

កម្មកិតតាមខ្លួនមិនដែលឃ្លាត  គ្រប់ប្រាំរយជាតិមិនដែលឆាប់

សត្វជ្រូកមាន់ទាគេចាក់កាប់  សំរាប់គេស៊ីជាអាហារ។

សត្វគោក្របីដំរីសេះ  គេជិះគេទឹមជាធម្មតា

គេកាប់លក់សាច់ផ្តាច់សង្សារ  រកចិត្តមេត្តាករុណាគ្មាន។

រូបខន្ធរលត់រលាយទៅ  សល់នៅសង្ខារនិងវិញ្ញាណ

វេទនាសញ្ញានឹកស្រេកឃ្លាន  សន្និដ្ឋានថាដូចអ្នកមានគុណ។

សត្វញីសត្វឈ្មោលអន្ទោលទុក្ខ    អាពុករឺម្តាយពីជាតិមុន
ជាតិមកពីរងទោសទុក្ខធ្ងន់    ក្រែងស៊ុនទៅលើសាច់ញាតិអែង។
ជ្រូកគោក្របីនៅតូចស្មាវ    គេក្រៀករះក្រៀវឃើញស្តែងៗ
បើគិតអោយសព្វគ្រប់កន្លែង    ជូនក្រែងជាតិមនុស្សមកជាសត្វ។
អ្នកពឹងនិងអ្នកធ្វើដៃដល់    ចៅក្រមអកុសលជំនុំកាត់
បញ្ជីទាំងពីរឈ្មោះមិនបាត់    គេចាត់ធ្វើទោសទាំងអស់គ្នា។
មិនមានអ្នកាណាធ្ងន់ណាស្រាល    យមភ្ពបាលរះក្រៀវគ្រប់វេលា
មានលោកយមរាជរាជសភា    ជំនុំគិតគ្នាមើលបញ្ជី។
បញ្ជូនអ្នកធ្វើចុះនរក    ជំនុំឃុំទុកអ្នកទិញស៊ី
ទិញសត្វស្លាប់រស់ទោះឈ្មោលញី    ទាំងពីរចំណែកចំណាំមុខ។
អ្នកមួយទិញស៊ីមិនរួចខ្លួន    ត្រឹមអែត្រីអួនយួនដូរលក់
អណ្តែងក្រាញ់ឆ្តោដៀបរស់ផ្ទក់    ចង់ទិញស្ងោរជ្រក់ទៅតថ្លៃ។
ឃើញច្បាស់ជារស់មិនទាន់ងាប់    អង្គុយបង្គប់អោយយួនវ៉ៃ
រកខ្យល់ច្រលោតដោតញ័រដៃ    ឃើញក្បែយស្រាប់ៗមិនទិញយក។
អានេះបន្ទូរលែងមិនបាន    ត្រូវច្រំផាក់ច្រានអោយជ្រុលជ្រក
ទំលាក់អោយជ្រៅរងទុក្ខសោក    លែលកអ្នកទោសរឿងអ្នកទិញ។
អ្នកទៅឃើញត្រីនៅបំរះ    វេទនាចិត្តណាស់ប្រាសដើរចេញ
អ្នកនេះត្រូវលែងអោយទៅវិញ    មានសែហ្វលិញគិញក្នុងនរក។
អោយជូនខ្លាចក្រែងវង្វេងផ្លូវ    ត្រូវមើលខុសត្រូវគ្រប់ភូមិស្រុក
បើកក្រាំងសៀវភៅកត់ឈ្មោះទុក    បញ្ជីពីរមុខបាបនិងបុណ្យ។

៣០ ប្រគល់យមរាជយម្ពុបាល ដាក់ស្រាលដោយស្រាលធ្ងន់ដោយធ្ងន់
អ្នកសាងមគ្គផលស្គាល់ទោសគុណ ទៅសោយសុខមុនតាមទុនទាន។
អ្នកសាងធុនទាបភាពអកុសល មិនចង់បានផលសួគ៌និព្វាន
ប្រព្រឹត្តអាក្រក់រកល្អគ្មាន មិនហ៊ានកាន់សីលថាខ្លាចដាច់។
មិច្ឆាទិដ្ឋិចូលពេញទី បញ្ជីសំរាំងតាំងសំរេច
ចុះវង្សអាជីវកត្លក់ស៊ីអាច់ ព្រោះពោលបង្កាច់ព្រះពុទ្ធិកា។
វចីទុច្ចរិតមានគ្រប់យ៉ាង ទានសីលមិនសាងអាងផឹកស្រា
លើលោកសំដែងធម៌ទេសនា ពិរោះពិស្តារមិនដឹងស្តាប់។
អស់យើងគួរស្តាយជាតិកំណើត សំណាងមកកើតក្នុងភទ្ទកប្ប
អគារិនិ័យព្រះប្រញប្ត ជាវិសេគល់ច្បាប់គួររក្សា។
៣៥ សីល៥ ចងចាំអោយប្រាកដ កុសលកម្មបថ១០ប្រការ
កុំឈ្លោះប្រកែកពីធម៌អាថិ ប្រកាន់សាសនាអោយប្រាកដ។
កើតមកជាមនុស្សមានសខ្មៅ មានប្រាជ្ញមានខ្លៅមានក្រខ្សត់
មានខ្លាំងមានខ្សោយដោយបែបបទ សន្មតថាល្អក៏មិនបាន។
ជម្ពូទ្វីបនេះមនុស្សកម្មក្រាស់ ព្រះពុទ្ធតែងត្រាស់មិនដែលខាន
ហេតុនេះមហាជនទាំងប៉ុន្មាន សំរាកសំរាន្តសំរួលចិត្ត។
បំណាច់សម្តេចព្រះទ្រង់ញាណ កាលហៀបនិព្វានមានកំរិត
ផ្តាំមហាអានន្ទអោយអាណិត អានុជអ្នកប្រឹតប្រោសសត្វផង។
សត្វផុងទសក្នុងជ្រោះជ្រាំជ្រៅ តថាគតទៅនាំចំលង
ដាក់ដល់និព្វានអស់ឬត់ឬង រួចពីចំណងវដ្តសង្សារ។

៤០ នៅសល់សង្ស័យសត្វខាងក្រោយ　　នន្ទអើយទុកអោយព្រះសិអារ្យ
អាណិតសត្វណាស់ណាអ្នកណា　　តថាគតជិតនិព្វានហើយ។
ព្រះអោស្នព្រះអង្គល្មមស្រណោះ　　សប្បុរសទាំងអស់កុំកន្តើយ
ប្រះខ្នងដេកលើកកន្ទេលខ្នើយ　　កុំស្ងៀមមាត់ឡើយរំលឹកគុណ។
ខ្លួនខ្ញុំកំណើតពាស្រ្តអ្នកស្រែ　　ខូចខិលខ្ជិលដែរពីកាលមុន
កាលមោហ៍បាំងបិទងងឹតស៊ុន　　ធ្វើបាបនិងបុណ្យទំងន់ស្មើ។
មិនស្មោះតែរូចចតុរាបាយ　　អស់លោកទាំងឡាយកុំសរសើរ
ខ្ញុំជូនដំណឹងតាមដំណើរ　　ព្រោះខ្ញុំគ្រាន់បើជាងអ្នកល្ងង់។
ជាតិក្រោយកុំអោយខ្ញុំល្ងីល្ងើ　　ជាតិនេះចាស់ស្ទើរខ្ញុំប្រឹងស្នង់
ប្រឹងស្ទុះអោយរួចពីអន្លង់　　ភ័យភិតខ្លាចផុងទៅក្នុងភក់។
៤៥ ក្នុងភពសង្សារខ្ញុំសង្ស័យ　　សព្វថ្ងៃខ្ញុំភ័យខ្លាចនរក
ម្យ៉ាងទៀតខ្ពើមជាតិអាជីវក　　ជាតិល្មោភហួបល្មក់ព្រោះល្មិលគុណ។
ច្រើនល្មើសបន្ទូលបន្ទោសព្រះ　　ខ្ញុំភ័យខ្ញុំណាស់ក្រែងខ្ញុំស៊ុន
ខ្ញុំសូមស្មាលាទោសពីមុន　　សូមបុណ្យជួយបាំងបាបអោយបាត់
អោយបានទាន់តួព្រះសិអារ្យ　　អោយបែកប្រាជ្ញាឆ្លាតបរមត្ថ
ព្រះអង្គទេសនាទ្រង់ប្រោសសត្វ　　សូមលុះអរហត្តដូចបំណង។
បំណាច់ខ្ញុំផ្សាយច្បាប់រំលឹក　　អស់លោកជួយនឹកសច្ចាផ្សង។
ធ្វើបុណ្យចែកផលដក់ខ្ញុំផង　　នឹកឈ្មោះម្តងៗដូចធម្មតា។
សប្បុរសប្រុសស្រីគប្បីស្តាប់　　ឈ្មោះច្បាប់កន្លងព្រះអោង្ការ
អោកាសអោយគិតប្រិតប្រាថ្នា　　ទាន់ព្រះសិអារ្យទាំងប្រុសស្រី។

កុំរៀនព្រហើនប្រហែសធ្វេស　　កើតក្នុងប្រទេសរាជបុរី
អោយមានបារម្ភភ្ជាក់ស្មារតី　　សីប្រាំ ប្រាំបីខំសិក្សា។
ជាតិមនុស្សជាន់ខ្ពស់ពីបុរាណ　　គេបានជួបដាក់ឃើញភក្ត្រា
បានគ្រងវងត្រាប់ព្រះពុទ្ធដិកា　　បានលុះសោតាអរហត្តហោះ។
យើងទាន់តែត្រឹមពាក្យបណ្តាំ　　បណ្តូលសីល៥ជាកេរ្តិ៍កោះ
កិច្ចការកងកម្មចាំមិនអស់　　របស់វិសេគល់គួររក្សា។
នេះចប់ចំណែកខាងបាសក　　កុំធ្វើអាក្រក់រាល់រូបបា
រំពឹងក្រែងចូលព្រះសិអារ្យ　　នមស្សការគោរពរំលឹកគុណា។
ព្រះចមច្រកពង្សមុនីនាថ　　កំពូលផុតជាតិជាងមហាជន
ទ្រង់សោយសម្បត្តិសំបើមបុណ្យ　　សំបូណ៌លើសលន់លុបលោកា។
លោកកីយដឹងហើយគួរកោតខ្លាច　　ទ្រង់មានអំណាចព្រះចេស្តា
គួរស្តាប់ព្រះរាជអោង្ការ　　បន្ទូលត្រួតត្រាគួរគ្រងត្រាប់។
ព្រះទ័យទ្រង់ត្រេកស្រលាញ់សង្ឃ　　ប្រមាណសែនអង្គក្នុងភទ្ទកប្ប
ព្រះពុទ្ធទ្រង់ប្រិតប្រាមប្រញប្ត　　ឈ្មោះច្បាប់បាដិមោក្ខសំវរសីល។
ចែកចេញជាកងសិក្ខាបទ　　កំណត់ពីរយម្ភៃប្រាំពីរ
មិនអោយមានមោះហ្មងមន្ទិល　　អ្នកបួសកុំខ្ជិលកាន់អោយខ្ជាប់។
បាណាអទិន្នាជាបឋម　　ជាតិរូបទៀតផ្សំត្រូវជាដប់
លោកសង្ឃអិលូវកាន់មិនសព្វ　　កាន់ក្នុងបន្ទប់លាយបន្លំ។
បន្លិចលុយកាក់សំងាត់　　ទោសត្រូវអាបត្តិលាក់សំងំ
បាសកធ្វើទានគ្មានអារម្មណ៍　　សន្សំតែទ្រពក្តៅក្រហាយ។

ប្រសិនបើកាន់ច្បាប់ព្រះពុទ្ធ    មិនមានធម្មយុត្តិមហានិកាយ
បើចេះខ្លាចក្រែងមិនខ្លែងក្លាយ    សមសុខសប្បាយមិនទាស់គ្នា។
លោកសង្ឃគ្រប់វត្តមានធំតូច    សង្ឃខ្លះខិលខូចសង្ឃខ្លះជា
បរិស័ទថ្កោលទោសគ្រូអុបជ្ឈាយ៍    មានពាក្យនិន្ទាតែរាល់វត្ត។
បាដិមោក្ខពីររយម្ភៃប្រាំពីរ    អ្នកល្ងង់ហើយខ្ជិលចាំមិនស្ទាត់
កងបាចិត្តិយនិងទុក្កដ    ចូលមាត់ចូលកមិនដឹងខ្លួន។
កងបាចិត្តិយកៅសិបពីរ    និស្សគ្គិយ៍សាមសិបបារាជិកបួន
បើចេះហើយចាំអោយមាំមួន    ល្អបរិសុទ្ធសួនមិនសាយសុស។
ប៉ុន្តែសិក្ខាមិនសូវចាំ    ចំណាំត្រង់ណោះចោលត្រង់ណោះ
ត្រង់ណាដែលដឹងជាខ្លួនខុស    ហ៊ានឈ្លោះពីព្រោះគេមិនដឹង។
សង្ឃាទិសេសប្រហែសបាន    ដប់បីសន្តានប្រមាណថ្លឹង
បើធ្លប់សង្រួមអោយយ៉ាងតឹង    មិនអរមិនខឹងមិនខាតខុស។
អិន្ទ្រិយ៍ប្រាំមួយនាំអោយភ្លាត់    បាចិត្តយ៍ទុក្កដលាយចំរុះ
អិន្ទ្រីយ៍ត្រចៀកភ្នែកច្រមុះ    ភ្នែកមើលណោះណោះឃើញសុសសាយ។
សោតិន្ទ្រីយោស្ទូវតិចខ្លាំង    ចក្ខុន្ទ្រីយំឃើញជិតឆ្ងាយ
ជីវ្ហិន្ទ្រីយាពោលនាយអាយ    សើចលេងសប្បាយចំអន់គ្នា។
បរិស័ទអាបត្តិទុក្កដញឹក    បារាជិកច្រើនណាស់តែអុបជ្ឈាយ៍
ទ្រព្យក្នុងសំបាច់សំបូណ៌ហៀរ    ត្រូវទោសអទិន្នាគរុភណ្ឌ។
ទ្រព្យសង្ឃជាដើមគឺចំណាំ    អវហារម្ភៃប្រាំចាំគ្មេរគ្មាន់
អោបទុកខ្លះខ្មែងក្រែងមិនគ្រាន់    អវហាប្រាំជាន់បារាជិក។

៧៥ ម្យ៉ាងទៀតទ្រព្យសង្ឃក្នុងចំណែក កិបទុកមិនចែកអោយលោកភិក្ខុ
គ្រឿងយារជីវិតកាលិក ទុកខូបល្វាចព្រឹកម៉ៅតែអែង។
ម្យ៉ាងទ្រព្យគេហែចូលវិហារ បាសកបូជាដល់គម្ពែង
គេវេរបាលីមានខ្លីវែង គេតែងនឹងថាសង្ឃស្ស។
ប្រកាសប្រគេនជំនុំសង្ឃ ចំពោះគ្រប់អង្គថាទេមៈ
លោកសង្ឃសាធុគ្មានសល់ម្នាក់ សង្ឃរាជទុកដាក់មិនចែកចាយ។
ខ្ញុំបាទតែងតាមខ្ញុំចេះចាំ អរហោរម្តេប្រាំបែបបរិយាយ
នេះសុទ្ធតែសីលផ្លូវអន្តរាយ លោកសង្ឃទាំងឡាយកុំប្រព្រឹត្ត។
ពីព្រោះអិន្រ្ទីយ៍ទាំង៦ លោកណាមិនព្រួយមិនប្រុងគិត
លោភោមោហោបាំងជិត សិស្សមានគំនិតមិនហ៊ានថា។
៨០ សូមទានសន្តោសសំដែងច្បាប់ ព្រះសង្ឃកុំចាប់ចងទោសា
ខ្លួនខ្ញុំសូមសុំបវារណា ប្រោសប្រាណមេត្តាគ្រប់បណ្តាសង្ឃ។
ខ្ញុំមិនមានពោលពាក្យបង្កាច់ ខ្លាចសីលលោកដាច់ខ្ញុំតំរង់
តំរូវតែតាមច្បាប់ព្រះអង្គ ព្រះអោស្នត្រឹមត្រង់ត្រូវមាត្រា។
កាលអង្គសំដេចព្រះចមភព បន្ទូលប្រោរព្វគ្រប់ប្រការ
ប្រកាសប្រាកដបទសិក្ខា ប្រញប្តប្តេជ្ញាមហាបរិស័ទ។
ភិក្ខុភិក្ខុនីអស់អរហន្ត អានន្ទមិនទាន់បានអរហត្ត
ព្រះធម៌វិន័យកុំអោយបាត់ ប្រយ័ត្នអោយគង់ប្រយោជន៍យូរ។
ក្រោយនោះព្រះអង្គចូលនិព្វាន អរហន្តហោះធ្យានមានជាគ្រូ
មិនមានអ្នកណាដាក់ទូ ទេសនាបង្ហូរពីព្រះអោស្ន។

៨៥ ព្រះអគ្គសាវ័កគ្រប់ព្រះអង្គ ព្រះទ័យស្រោចស្រង់ទ្រង់សន្តោស
សំដែងធម៌អាថ៌មេត្តាប្រោស បាបបុណ្យគុណទោសនិងសីលទាន។
ឈ្វេងយល់ថាធម៌នឹងសូន្យស្ងាត់ អហន្តអរហត្តចូលនិព្វាន
សង្ឃសេក្ខបុគ្គលមិនទ្រង់ញាណ មិនមានអ្នកណាតែងទុក។
ព្រះធម៌ប្រាំបីម៉ឺនបួនពាន់ ស្រេចលើអានន្ទចាំទំនុក
ដំនៃលព្រះអង្គដឹងគ្រប់មុខ ជង្រុកធម៌អាថ៌មហាអានន្ទ។
ជាព្រះអនុជអាណិតសត្វ ក្រែងបាត់បិដកមិនគ្រប់គ្រាន់
ព្រះធម៌ប្រាំបីម៉ឺនបួនពាន់ គ្មេរគ្មាន់ខ្ចះខ្ចែងចាត់ចែងចារ។
ចេះចប់អភិធម្មចាំរហូត វិន័យព្រះសូត្រ ៥ប្រការ
ប្រកាសអស់អង្គអរហន្តា បិដកអែណាជាវិសេគល់។
៩០ បមត្តព្រះសូត្រអានន្ទចាំ វិន័យទាំង៥ អុបាលីយល់
អរហន្តទាំងអស់កើតរវល់ អំពល់អីពីរឿងធម៌អាថ៌។
ព្រះបាទអជាតៈសត្រូវ ជួយគិតតំរូវព្រះសាសនា
សម្មតិអោយឈ្មោះហៅក្សត្រា ព្រោះព្រះមហាក្សត្រីយចូលគំនិត។
និយាយអោយដឹងដើមកំណើត កកើតអក្ខរាចារស្លឹករិត
បកប្រែបាលីសេចក្តីពិត ពិនិត្យត្រឹមត្រូវតាមពុទ្ធដិកា។
ទសជាតក៍ទាំង១០មានគ្រប់វត្ត ប្រែត្រូវប្រាកដព្រះគាថា
ព្រះធម៌សូត្រមន្តវីសូត្រដារ អ្នករៀនអក្ខរាពីរចំណែក។
ចំណេះចំណាំចាំដោយខ្លួន ខ្លះរៀនមានក្បួនចាស់ចារចែក
ហ៊ានភ្នាល់ព្រោះអាងឃើញនិងភ្នែក កើតឈ្លោះប្រកែកប្រកួតខឹង។

៩៥ ប្រកាន់តែខាងខុសរហូត មិនរៀនមេសូត្រអោយចេះដឹង
អាងចេះតែ ក កា ប៉ុណ្ណឹង ខំប្រឹងចំអើតអួតខ្លួនត្រូវ។
ក្តៅណាស់ពីរឿងយោជាយ៉ោ តំលើងភ្នែកស្លោមុខក្រញូវ
ថាធ្លាប់យោនាពីខ្មោចអូវ អិលូវយ៉ោណាមិនសុខចិត្ត។
អ្នកម្ខាងអាងស្រះតួប្រាំបី អោយដឹងបាលីជាកំរិត
ផ្សំតួមេសូត្រប្រឹងប្រែប្រឹត ព្រោះត្បិតអោយត្រឹមត្រូវមាត្រា។
អ្នកបួសគ្រប់វត្តគ្រប់នគរ ស ដាក់ជើង ល រាប់ស្លស្លា
បើ ស ជើង ម រាប់ ស្មស្មា នាក់មានប្រាជ្ញាល្មមស្តាប់បាន។
កុំលូង់ទាល់ងាប់ធ្លាប់មិនដឹង បើខឹងខ្ញុំឃាត់ថាអោយខាន
ខ ដាក់ជើង ម ពីបុរាណ ក្មេងតូចប៉ុន្មានស្គាល់ ខ្មខ្មា។
១០០ ជាតិរាស្រ្តចាស់ក្មេងកុំចិត្តខ្មាំង គួរខ្មាសបារាំងអ្នករាជការ
ដើមហេតុអំពីព្រះករុណា អោយសាងសាលាប្រែបាលី។
ទ្រង់ចាំទំនៀមពីបុរាណ ហើយបានជំនុំព្រមកុង្សីយ
បំណាច់ធ្វើស្តេចគ្រងផែនដី ទិសទាំងប្រាំបីរំពៃគ្រប់។
ព្រះកាយពលមិនរវល់រែក ព្រះទ័យរំលែកទាំងថ្ងៃយប់
ចូលទែនបន្ទំទីបន្ទប់ បន្ទូលមិនឈប់រាល់វេលា។
មេត្តាប្រោសប្រាណអ្នកមានស័ក្តិ ប្រទានលុយកាក់គ្រប់ភ្នាក់ងារ
ទ្រង់ត្រួតស្រ្តីស្នំស្រីង្គារ ក្រែងគ្រុនរងារមិនបានសុខ។
ព្រះទ័យមេត្តាសព្វមនុស្សសត្វ សោយរាជសម្បត្តិសំបើមស្តុក
ព្រះកាយប្រកបគង់ស្រណុក ព្រះទ័យវិតក្កជាធម្មតា។

១០៥ មួយព្រួយនឹងអោបព្រះនគរ ពីរព្រួយនឹងពព្រះសាសនា
បើត្រូសលោកសង្ឃកាន់សិក្ខា សង្រួមកិរិយាមិនបរិសុទ្ធ។
នឿយណាស់ព្រះនេត្រព្រះកាណ៌ា ព្រះអោស្ឋត្រួតត្រាច្រើនបំផុត
ដាស់តឿនបំភ័យពួកកុលបុត្រ អោយប្រុងលំអុតសង្រួមកាយ។
បានចេញប្រកាសដាក់ប្រាកដ ប្រគេនគ្រប់វត្តនោះជិតឆ្ងាយ
លោកសង្ឃមិនត្រូវស្រើបសប្បាយ អស់ល្បែងទាំងលាយគ្រប់ចំពូក។
មិនត្រូវចំពោះស្តាប់តន្ត្រី កុំបីមើលរាំវានាំភ្លូក
កុំដើរភ្លើៗមើលអុំទូក អ្នកបួសធ្វើលោកមិនត្រូវការ។
បើមានត្រូវកិច្ចដើរយប់ថ្ងៃ សង្ឃបងនិស្ស័យចាស់វស្សា
កុំដើរទឹមស្មាទៅណាៗ អ្នកចេះសិក្ខាគេទាស់ភ្នែក។
១១០ លោកនេនកុំសុំលុយចិនចាយ បិណ្ឌបាតតែបាយម្នាក់១វែក។
គ្រឿងម្ហូបចំណីបាសកចែក កុំស្តាយពុនវែកវាថោករិក។
របស់បាសកគេប្រគេន ប្រគល់លោកនេនបានលោកភិក្ខុ
ចិញ្ចឹមជីវិតនិងបាយទឹក បិណ្ឌបាតតែព្រឹកយប់សូត្ររៀន។
លោកណាត្រឹមត្រូវមិនសូវខុស ស្ងៀមស្ងាត់ទៅចុះកុំអន់អៀន
លោកណាមិនចេះកុំវេះរៀន ពាក្យប្រៀនប្រដៅអោយផ្ទើលភ្ញាក់។
ពីព្រោះព្រះអង្គបានផ្តាំផ្ញើ វិន័យស្ថិតលើស្តេចមហាចក្រ
ព្រះមហាចមពង្សទ្រង់ជំពាក់ ចំពោះធុរៈនឹងសាសនា។
ពីត្រឹមនោះរៀងដរាបមក ដល់ស្រុកគោកធ្លកមានសារតារ
ប៉ុន្មានរាជ្យហើយមិនដឹងថា ដល់មកករុណាយើងសព្វថ្ងៃ។

១១៥ ហេតុនេះលោកសង្ឃប្រុងពិនិត្យ    សៀវភៅស្លឹករិតមានរាល់ដៃ
ផ្ទៀងមើលសិបផូករិនិច្ឆ័យ    បើនៅសង្ស័យអោយសិក្សា។
លោកសង្ឃចាស់ខ្ចីគប្បីស្តាប់    ឈ្មោះច្បាប់គន្លងព្រះពុទ្ធដិកា
បង្គំថ្វាយដល់ព្រះករុណា    សូមទ្រង់មេត្តាជ្រាបព្រះទ័យ។
ក្រែងជួបប្រទះពាក្យឆ្គាំឆ្គង    ពុំត្រូវទំនងក្រិត្យវិន័យ
សូមទានសន្តោសអត់ទោសពៃ    ក្រួញក្រាបសិរសីក្រោមព្រះបាទ។
ព្រះសង្ឃទាំងអស់ទោះតូចធំ    អភ័យទោសខ្ញុំសូមអនុញ្ញាត
ពាក្យខ្ញុំមិនមានពោលប្រមាថ    សង្ឃជាល្អស្អាតខ្ញុំមិនថា។
ខ្ញុំពោលតែលោកធ្វើអាក្រក់    បើខ្ញុំកុហកខុចមុសា
ហេតុនោះខ្ញុំសូមបវារណា    និដ្ឋិតាសង្ខេបតែប៉ុណ្ណោះ។
១២០ ក្មេងណាប្រាថ្នាបួសធ្វើសង្ឃ    អោយស្វែងតំរង់រៀនតំរេះ
អោយមើលតំរាប់លោកអ្នកចេះ    កុំដេកតែអេះតិះដៀលគ្នា។
អ្នកម្តាយអូវពុកអោយឈ្មោះអ៊ូ    ពូជពង្សអំបូរខ្មែរអ្នកជា
អាពុកឈ្មោះ អ៊ុក មានស័ក្តិងារ    ចៅពញាធម្មធារាធ្វើមេស្រុក។
ក្នុងខែត្រភ្នំពេញឃុំកំបូល    ជាប់ដៅត្រកូលម្ចាស់អង្គ ប៉ុក
អាពុកអ្នកម្តាយឈ្មោះពញា ម៉ុក    គាត់ធ្វើមេស្រុកឃុំស្ពានថ្ម។
អ្នកម្តាយអាពុកបងប្អូនជិត    ជីទូតមួយពិតពូជចិត្តល្អ
ជូនតាផ្សំផ្គុំជាតំណ    បង្កកើតខ្ញុំទូលបង្គំ ។
បង្កើតពីដើមគំនិត    ភ័យភិតខ្លាចបាបចង់បានបុណ្យ
បានបែកថែងច្បាប់ប្រាប់មហាជន    បួនច្បាប់ពីមុនជូនរាជការ។

១២៥ បោះពុម្ពសៀវភៅចែកសព្វសាយ បណ្ណាល័យចាត់ថ្វាយព្រះករុណា
មិនបានថ្វាយផ្ទាល់ដល់ហត្ថា សូមទ្រង់មេត្តាប្រោសប្រណី
អោនកាយប្រណម្យសូមអនុញ្ញាត ក្រាបក្រោមព្រះបាទព្រះបារមី
ចែងច្បាប់បរមត្ថអត្ថបាលី សេចក្ដីចែងចប់ម្ល៉េះហើយហោង។

ព្រះភិរម្យភាសា អ៊ូ ហៅ ង៉ុយ